ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ.......✓...........

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការពារជាតិមានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា តបតាមសំណើរបស់សហព័ន្ធរុស្ស៊ី ក្នុងការចូលសំចតនាវាយោធាកងទ័ពជើងទឹករុស្ស៊ី ចំនួន០៣គ្រឿង ឈ្មោះ **Rezky (343), Hero of the Russian Federation Aldar Tsydenzhapov (339)** និង **Pachenga** ដែលមាននាវិកសរុបចំនួន៣២០នាក់ ដឹកនាំដោយ វរនាវីឯក **ALEKSEI ANTSIFEROV** នាយសេនាធិការ ផ្នែកនាវាលើផ្ទៃទឹក កងនាវាប៉ាស៊ីហ្វិក នៃសហព័ន្ធរុស្ស៊ី បានចូលសំចតនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចាប់ពីថ្ងៃទី២៨ ខែមេសា ដល់ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៥។ ការចូលសំចតនាវារបស់កងទ័ពជើងទឹករុស្ស៊ីនេះ ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការល្អ បង្កើនទំនាក់ទំនង និងរឹតចំណងមិត្តភាព សាមគ្គីភាព ឱ្យកាន់តែល្អឡើងទ្វេដងថែមទៀត រវាងប្រទេសទាំងពីរ កម្ពុជា-រុស្ស៊ី។ គួរគូសបញ្ជាក់ផងដែរថា ចាប់ពីឆ្នាំ២០១១ មកដល់ពេលនេះ មាននាវាចម្បាំងរុស្ស៊ីចូលចតចំនួន៧លើក ដែលស្មើនឹងនាវាចំនួន១៦គ្រឿង។

ក្នុងអំឡុងពេលចូលសំចតនាវានៅក្នុងប្រទេសកម្ពុជារយៈពេលបួនថ្ងៃនេះ គណៈប្រតិភូនាវាបានរៀបចំផែនការសកម្មភាពដែលបានគ្រោងទុករួមមាន ជំនួបពិភាក្សាការងារជាមួយ មេបញ្ជាការមូលដ្ឋានសមុទ្ររាម ជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ នៃគណៈអភិបាលខេត្តព្រះសីហនុ សកម្មភាពផ្លាស់ប្តូរវប្បធម៌ និងលេងកីឡាមិត្តភាពជាមួយនាវិកកម្ពុជាក្នុងន័យលើកកម្ពស់ភាពស្និទ្ធស្នាល។

ទស្សនកិច្ចខាងលើនេះ ជាព្រឹត្តិការណ៍សំខាន់មួយទៀត នៃទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី ឱ្យកាន់តែប្រសើរឡើងថែមទៀត។

ថ្ងៃ អង្គារ ៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៨ អ៊ីមែល៖ generalsec@mod.gov.kh